**សុន្ទរកថា**

**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ថ្លែងក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នីតិវិធីស្ដីពីការចុះបញ្ជី**

**អ្នករស់នៅជាមួយមេរោគអេដស៍ទៅក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**

សណ្ឋាគារកាំបូឌីយ៉ាណា ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២

សូមគោរពអង្គពិធីទាំងមូល

- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងផែនការ
- **ឯកឧត្តមវេជ្ជបណ្ឌិត ឆា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- **ឯកឧត្តមវេជ្ជបណ្ឌិត ឡូ វាសនាគីរី** រដ្ឋលេខាធិការក្រសួងសុខាភិបាល
- លោកស្រី **Patricia Ongpin** នាយិកាអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា
- លោកស្រី **Alissar Chake** តំណាងអង្គការ UNDP ប្រចាំប្រទេសកម្ពុជា
- **លោកវេជ្ជបណ្ឌិត Sok Bunna** អ្នកឯកទេសគ្រប់គ្រងគម្រោងកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍ នៃទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក **USAID**
- លោកស្រី **Corinna Heineke** នាយកគម្រោងលើកកម្ពស់គាំពារសង្គម និងសុខភាព អង្គការ GIZ
- លោក **សឿម សុផល** ប្រធានកម្មវិធីបណ្ដាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា
- **ឯកឧត្តម និងលោកជំទាវ អស់លោក លោកស្រី តំណាងរាជធានី ខេត្ត**
- លោក លោកស្រី តំណាងអង្គការសង្គមស៊ីវិល ប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍

ថ្ងៃនេះ ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្ដីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល តំណាងប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ ចំពោះការចូលរួមក្នុង **ពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នីតិវិធីស្ដីពីការចុះបញ្ជីអ្នករស់នៅជាមួយមេរោគអេដស៍ ទៅក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** នៅសណ្ឋាគារកាំបូឌីយ៉ាណា នាពេលនេះ។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការដែលបានផ្ដល់ការគាំទ្រផ្នែកនយោបាយក្នុងការចុះបញ្ជីអ្នករស់នៅជាមួយមេរោគអេដស៍ ទៅក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា។ ខ្ញុំក៏សូម

ថ្លែងអំណរគុណចំពោះ ឯកឧត្តម **កែវ ឆ្វៀលី** អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ អង្គការ **GIZ USAID UNDP** និង**UNAIDS** ចំពោះការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីរៀបចំដំណើរនីតិវិធីចុះបញ្ជីអ្នករស់នៅជាមួយនឹងមេរោគអេដស៍ ទៅក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅគ្រប់កន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍ទូទាំងប្រទេស។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

មុននឹងឈានទៅដល់ប្រធានបទនៃកិច្ចគាំពារសង្គម ខ្ញុំសូមធ្វើបច្ចុប្បន្នភាពអំពី វឌ្ឍនភាព សមិទ្ធផល និងការឆ្លើយតបទៅនឹងជំងឺអេដស៍នៅកម្ពុជា។

- ប្រៀបធៀបនឹងគោលដៅ៩៥-៩៥-៩៥ របស់អង្គការUNAIDS កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដោយក្នុងនោះ ១) អ្នកផ្ទុកមេរោគអេដស៍ចំនួន៨៤% បានដឹងពីស្ថានភាពរបស់ពួកគេ ២) ក្នុងចំណោមអ្នកដែលបានដឹងពីស្ថានភាពរបស់ពួកគេ៩៩% កំពុងទទួលឱសថប្រឆាំងមេរោគអេដស៍ និង៣) ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ដែលកំពុងទទួលការព្យាបាល ៩៧%មានអត្រាមេរោគអេដស៍ក្នុងឈាមកម្រិតទាបបំផុត។
- ក្នុងចំណោមប្រទេសនៃតំបន់អាស៊ី និងប៉ាស៊ីហ្វិក យើងជាប្រទេសទីពីរនៅលើគោលដៅ ៩៥ទីមួយ និងប្រទេសទីមួយនៅលើគោលដៅ៩៥ទីពីរ។
- ក្នុងពេលដែលប្រទេសកម្ពុជាកំពុងឆ្ពោះទៅរកនិរន្តរភាព នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនថា រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ផ្តល់ថវិកាចំនួន១៥លានដុល្លារអាម៉េរិក សម្រាប់ជាសហហិរញ្ញប្បទានលើគម្រោងសំណើមូលនិធិសកលកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពីឆ្នាំ ២០២៤ដល់ឆ្នាំ២០២៦។
- ការគាំពារសង្គម និងការឆ្លើយតបនឹងមេរោគអេដស៍
  ក. នៅកម្រិតពិភពលោក យើងបាននិងកំពុងអនុវត្តគោលការណ៍សូន្យបីគឺ សូន្យការឆ្លងមេរោគអេដស៍ថ្មី សូន្យការរើសអើង សូន្យការស្លាប់ពាក់ព័ន្ធនឹងជំងឺអេដស៍។ នៅឆ្នាំ ២០២១ តាមរយៈសម័យប្រជុំពិសេសរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ អង្គការសហប្រជាជាតិបាននឹងកំពុងអំពាវនាវឱ្យប្រទេសទាំងអស់បញ្ចប់វិសមភាព ដែលកំពុងរារាំងប្រជាជនក្នុងការទទួលបាននូវអត្ថប្រយោជន៍ពី សេវាមេរោគអេដស៍ និងធានាថា ពិភពលោកពិតជាឈានទៅរកការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០៣០។
  ខ. នៅកម្រិតថ្នាក់ជាតិ ៖ ទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានអំពាវនាវដល់ជនរួមជាតិទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងចរន្តជាតិ (ពីក្បាលដល់ចុងជើង) ដើម្បីបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិងកំពុងចូលរួមជាមួយភាគីពាក់ព័ន្ធ ពីវិស័យសុខាភិបាល និងមិនមែនសុខាភិបាល ដើម្បីរួមចំណែកក្នុងការបញ្ចប់ជំងឺអេដស៍។ យុទ្ធសាស្រ្តទី៣ នៃផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៩-២០២៣ ត្រូវបានលើកឡើងដើម្បីកែលម្អលទ្ធភាពទទួលបានការគាំពារសង្គម និងសេវាសង្គមសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍។
- ផ្តើមចេញពីចក្ខុវិស័យនៃក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ ដែលរួមបញ្ចូលនូវអភិក្រមបរិយាប័ន្ន ប្រសិទ្ធភាព និងនិរន្តរភាពហិរញ្ញវត្ថុជាឧបករណ៍កាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព អ្នកតំណាងពីក្រុមប្រឹក្សាជាតិគាំពារសង្គមជាតិត្រូវបានតែងតាំងជា សមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចាប់តាំងពីខែមករា ឆ្នាំ២០២១មក។
- នៅឆ្នាំ២០២១ គ្រួសារដែលមានផ្ទុកមេរោគអេដស៍ចំនួន២៥០០ បានទទួលនូវអត្ថប្រយោជន៍ពីកម្មវិធីផ្ទេរសាច់ប្រាក់បន្ទាន់ដើម្បីកាត់បន្ថយផលប៉ះពាល់នៃកូវីដ-១៩។
- នៅខែកុម្ភៈ ឆ្នាំ២០១៩ ទីស្តីការគណៈរដ្ឋមន្រ្តីបានចេញដាក់ចេញនូវវិធានការគោលនយោបាយចំនួន៦ចំណុច ដើម្បីជានាចីរភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ នៅក្នុងលិខិតលេខ២១៣សជណ.សស។ វិធានការគោលនយោបាយទី២ អំពាវនាវដល់ក្រសួងសុខាភិបាល ក្រសួងផែនការ ឱ្យរៀបចំកំណត់ និងពិចារណាការចាត់ទុកអ្នកផ្ទុកមេរោគអេដស៍ជាក្រុមជនងាយរងគ្រោះ ដែលគួរទទួលបានមូលនិធិសមធម៌ ដើម្បីទទួលបានការធានារ៉ាប់រងសុខភាព និងការគាំពារសង្គម។
- ដោយមានការគាំទ្រពីអង្គការ **LHSS/USAID** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្កើតឧបករណ៍សម្រាប់តាមដានពិនិត្យការអនុវត្តវិធានការគោលនយោបាយ (រួមទាំងការគាំពារសង្គម) នៃលិខិតលេខ២១៣សជណ.សស របស់ទីស្តីការគណៈរដ្ឋមន្រ្តី។
- ការគាំពារសង្គមត្រូវបានរួមបញ្ចូល នៅក្នុងការត្រួតពិនិត្យដឹកនាំសហគមន៍នៃបណ្តាញប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ (Community Led Monitoring, CLM)។ នៅពេលថ្មីៗនេះ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្រ្តរបស់កម្ពុជាសម្រាប់ការបង្ការ និងថែទាំមេរោគអេដស៍ និងកាមរោគក្នុងវិស័យសុខាភិបាល ២០២១-២០២៥ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ភាគីពាក់ព័ន្ធទាំងអស់បានព្រមព្រៀងបញ្ចូលការគាំពារសង្គមជាសូចនាករមិនមែនសុខាភិបាល ទៅក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃថ្នាក់ជាតិ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

ឆ្លើយតបនឹងការអំពាវនាវដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កន្លងមក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននឹងកំពុងប្រើប្រាស់កញ្ចក់វិសមភាព (inequalities lens) ដើម្បីកាត់បន្ថយវិសមភាព និងភាពប្រឈមមុខនានា ដោយការអនុវត្តសសរស្តម្ភចំនួន៣គឺ ភាពជាអ្នកដឹកនាំ ភាពជាដៃគូ និងការវិនិយោគ។

ក្នុងន័យនេះ ខ្ញុំសូមជម្រាបជូនថា រាជរដ្ឋាភិបាលកំពុងបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង និងក្រុមស្នូល ដើម្បីតាក់តែងគោលនយោបាយជាតិក្នុងការបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងកម្មវិធីឆ្លើយតបពហុវិស័យប្រកបដោយចីរភាព នៅឆ្នាំ២០២៤-២០២៨។ វេទិកានេះនឹងអនុញ្ញាតឱ្យភាគីពាក់ព័ន្ធរួមទាំងអង្គការសង្គមស៊ីវិល និងបណ្តាញប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍រួមគ្នាបង្កើតចក្ខុវិស័យរួម និងយុរអង្វែងសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយនិរន្តរភាព។

ថ្ងៃនេះ ការដាក់ឱ្យដំណើរការនូវនីតិវិធីសម្រាប់ការរួមបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នឹងអនុញ្ញាតឱ្យបុគ្គលិកថែទាំអ្នកផ្ទុកមេរោគអេដស៍ និងសេវាថែទាំសុខភាពដែលធ្វើការនៅគ្រប់កន្លែងព្យាបាលដែលផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ( ART sites) ទាំង៧២កន្លែងនៅទូទាំងប្រទេសអនុវត្តអភិក្រមដែលផ្តោតលើប្រជាជន ( People-Centered Approach) ដើម្បីផ្តល់សេវាសុខភាពទូលំទូលាយដល់អ្នកជំងឺតាមតម្រូវការរបស់ពួកគេ។ បុគ្គលិកថែទាំសុខភាពដែលទទួលបានអត្ថប្រយោជន៍ពី ការគាំទ្រមូលនិធិសមធម៌ផ្នែកសុខភាពដល់អ្នកផ្ទុកមេរោគអេដស៍ទាំង៧៤.000នាក់ នៅទូទាំងប្រទេសអាចធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃសេវាសុខភាពមិនមែនគ្រាន់តែដើម្បីសម្រេចគោលដៅ៩៥-៩៥-៩៥ទាំងបីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការបង្ការរួមបញ្ចូលគ្នា ការលុបបំបាត់ការចម្លងពីម្តាយទៅកូន សុខភាពបន្តពូជ ការបង្ការការចម្លងជំងឺរបេង និងសេវាសុខភាពរួមបញ្ចូលគ្នាផ្សេងទៀត ( Integrated health services ) ផងដែរ។

ជាទីបញ្ចប់នេះ ខ្ញុំសូមអំពាវនាវដល់អ្នកចូលរួមទាំងអស់ក្នុង **ពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នីតិវិធីស្តីពីការចុះបញ្ជីអ្នករស់នៅជាមួយមេរោគអេដស៍ នៅក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** ថ្ងៃនេះ ឱ្យផ្តោតលើជនក្រីក្របំផុត និងប្រជាជនគន្លឹះដែលងាយនឹងទទួលការរើសអើងនិងមាក់ងាយ តាមរយៈការគាំទ្របណ្តាញរបស់ពួកគេ ដើម្បីទទួលបានអត្ថប្រយោជន៍ពីការគ្របដណ្តប់សេវាសុខភាពជាសកល (Universal Health Coverage) និងការគាំពារសង្គម ( Social Protection) នៅក្នុងខេត្ត ក្រុងរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ព្រមទាំងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីពង្រឹងមុខងារនៃបណ្តាញប្រជាជនគន្លឹះ អ្នកផ្ទុកមេរោគអេដស៍ទាំងនោះ នៅក្នុងប្រព័ន្ធជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបិទគម្លាតវិសមភាព និង

បង្កើនកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ ឈានទៅដោះស្រាយរាល់ការលំបាកនានា និងធ្វើសមាហរណកម្មការរួមចំណែកក្នុងការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ខាងមុខ។

ខ្ញុំសូមប្រសិទ្ធពរជ័យបវរមហាប្រសើរជូន ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកចូលរួមទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ។